ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ
តុលាការព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌលេខ ១២៩៥
ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០
សាលក្រមលេខ ១៥(ច)/៨៥
ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈ
នៅសាលាដំបូងខេត្តបន្ទាយមានជ័យ
នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ដែលមានសមាសភាពដូចតទៅៈ

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា
លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ឋានៈព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងខេត្ត

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៩៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted]សុធាប ភេទប្រុស កើតឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបិតស្រាសរលក់ កើតនៅឃុំ[redacted] ខេត្តព្រៃវែង អាសយដ្ឋានភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] ហាត ឪពុកឈ្មោះ [redacted]ធីរ "រ" ម្តាយឈ្មោះ [redacted]ញឹម "រ" ទោសពីមុនគ្មាន ជានីតិជន ។(ឃុំខ្លួនថ្ងៃទី២០-១១-២០២០)

**ជាប់ចោទពីបទៈ** ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] អៀប ភេទប្រុស អាយុ៥៥ឆ្នាំ អាសយដ្ឋាននៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

អង្គហេតុចោទប្រកាន់មានដូចតទៅ ៖ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្នុងកម្មវិធីជប់លៀងមួយកន្លែង ស្ថិតនៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឈ្មោះ [redacted]អៀប បានធ្វើកម្មភាពឌីដងដាក់ឈ្មោះ ហ៊ិន សុធាប ដែលកំពុងមានវត្តមានក្នុងកម្មវិធីជាមួយគ្នាបណ្តាលឲ្យឈ្មោះ [redacted] សុធាប មានអារម្មណ៍ខឹងនឹងឈ្មោះ [redacted]អៀប ហើយក៏បានដើរត្រឡប់មកផ្ទះវិញ ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ២០២១
ក្រឡាបញ្ជី
[redacted]

យកកាំបិតខ្មែរនៅផ្ទះយកទៅកាប់ឈ្មោះ [redacted] អៀប ដល់កន្លែងកម្មវិធីជប់លៀងចំនួន០១កាំបិតខ្មែរចំក្បាល ហូរឈាម (របួសធ្ងន់) ហើយឈ្មោះ [redacted] សុធាប ក៏បានរត់គេចខ្លួន។ បន្ទាប់មកនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០២០ ឈ្មោះ [redacted] សុធាប ក៏បានត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ ក្រោយបញ្ចប់ការស៊ើបអង្កេត សមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១១៥៥ អយក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥២៩០ ពស.ព្រស"គ"/២០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៤ ពស.ព្រជ"ក"/២០ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

**នាពេលសវនាការ**

ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ទាក់ទិនក្នុងសំណុំរឿង

ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង

ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបាន ស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តបន្ទាយមានជ័យ យល់ឃើញថា**

១. ជនជាប់ចោទឈ្មោះ [redacted] សុធាប ភេទប្រុស កើតឆ្នាំ១៩៧៣ (អត្តសញ្ញាណខាងលើ) ត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ បញ្ជូនមកជំនុំជម្រះពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សុធាប បញ្ជាក់ថា ខ្លួនកាប់គេមែន តែមិនចាំថ្ងៃទេ ហើយគាត់ [redacted] អៀប) មកកម្មវិធីផ្ទះខ្លួនហូបចុកហើយផឹកស្រាបៀរ ហើយខ្លួនផឹកមួយកំប៉ុងដែរ។ តែពេលនោះប៉ះពាល់សំដីប្រពន្ធខ្លួនហើយខ្លួន និយាយរឿងនេះក្តៅចិត្តដែរប្រពន្ធខ្លួនសុំលែង ហើយនាំមនុស្សប្រុសមកផឹកស៊ីខ្លួនមិនស្គាល់។ ខ្លួនឈ្លួលមួយពេលទើបយកកាំបិតផ្គាក់ទុកកាប់អុសក្បៀននោះ កាំបិតទុកកាប់ឆ្កាមែកឈើ។ ពេលខ្លួនដកផ្គាក់ទៅកាប់គាត់ថាមិនយកខ្លួនវិញទេ សុខចិត្តយកប្តីគេ ខ្លួនកាប់គេពីមុខដោយគេដឹងខ្លួនតែចាប់មិនទាន់ ចំក្បាលមួយកាំបិត គេរត់ខ្លួនដេញកាប់ដែរ តែគេរត់បាត់ហើយខ្លួនក៏មកវិញ ។ខ្លួនមិនចង់កាប់គេឲ្យស្លាប់ទេ។ ជនរងគ្រោះរបួសនៅផ្នែកខាងឆ្វេង ខ្លួនកាប់ដៃស្តាំ ពេលមុនកាប់ខ្លួននិយាយដែរថាផឹកទៅកុំនិយាយអី ខ្លួនមិនបានជជែកជាមួយជនរងគ្រោះទេ កាំបិតទុកនៅក្រោមផ្ទះក្បៀនទ្វារ គេជជែកយូរខ្លួនចុះមកមិនសួរនាំទេកាប់តែម្តង ខ្លួនមិនធ្លាប់មានទំនាស់ជាមួយជនរងគ្រោះទេពីមុនៗ

៣. តាមអំណាចចម្លើយជនជាប់ចោទឈ្មោះ [redacted] សុធាប បញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ នៅក្បែរផ្ទះរបស់ខ្លួនកម្មវិធីជប់លៀងផឹកស៊ីរាក់ ទើបខ្លួនដើរចេញពីផ្ទះសំដៅទៅកន្លែងកម្មវិធី

ថ្ងៃ... ខែ... ឆ្នាំ... ស័ក ព.ស.២៥៦៥

បន្ទាយមានជ័យ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០....

ក្រឡាបញ្ជី

[redacted]

ជំពូកទី 2

លុះទៅដល់ឈ្មោះ [redacted] អៀប ក៏បានស្តោះទឹកមាត់ដាក់រូបខ្លួន ព្រមទាំងធ្វើសកម្មភាពឌឺដងដាក់ខ្លួនទើបខ្លួនមានអារម្មណ៍ខឹង ហើយក៏បានដើរត្រលប់មកផ្ទះ រួចយកកាំបិតខ្វែវទៅកាប់ឈ្មោះ [redacted] អៀប ដល់កន្លែងកម្មវិធីវិញ។ ដោយខ្លួនបានកាប់ឈ្មោះ [redacted] អៀប ចំនួន០១កាំខ្វែវ ត្រូវចំហៀងក្បាលខាងមុខបណ្តាលឲ្យបែកក្បាលហូរឈាម ហើយខ្លួនក៏បានរត់គេចខ្លួន បន្ទាប់មកនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនដែលមានជម្លោះជាមួយឈ្មោះ [redacted] អៀប ទេពីមុនមក។ ហើយខ្លួនមិនបានទទួលទានស្រានៅថ្ងៃកើតហេតុដែល តែខ្លួនឃើញប្រពន្ធរបស់ខ្លួនបានរាំជាមួយឈ្មោះ [redacted] អៀប។

៤. នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀប បញ្ជាក់ថា គាត់និយាយមិនពិតទេ ថ្ងៃនោះមានកម្មវិធីលក្ខណៈគ្រួសារ ប្រពន្ធគាត់ និងប្រពន្ធខ្លួនជាមិត្តនិងគ្នា ហើយគាត់ហៅហូបបាយលក្ខណៈគ្រួសារ ហូបហើយខ្លួនអង្គុយលេងទូរស័ព្ទ ពេលនោះហូបស្រាអស់មួយកេះកន្លះគ្នាដប់នាក់។ ខ្លួនរៀបចំចេញមកផ្ទះហើយ គាត់មកកាប់មិនសួរនាំអ្វីទាំងអស់ កាប់រយះក្បាលសាមសិបប្រាំមួយថ្នេរ កាប់ពីមុខដោយមកស្ងាត់ៗ មិនដឹងខ្លួនមុនទេ។ ពេលនេះរបួសសះជាហើយពេទ្យស្កេនថាប្រេះលលាក្បាល កាប់ថ្ងៃទីប្រាំមួយដេកពេទ្យរយៈពេលប្រាំថ្ងៃការចំណាយលើប្រពន្ធ រួចមកដេកផ្ទះចំនួនបីថ្ងៃ ហើយខ្លួនបានទៅស្កេននៅពេទ្យបាត់ដំបងឃើញថាស្រាំលលា រាល់ថ្ងៃខ្លួននៅឈឺក្បាល ហើយភ្លេចច្រើន ខ្លួនមិនដែលមានគំនុំអីជាមួយជនរងគ្រោះនោះទេ ។ ហើយថ្ងៃនោះខ្លួនមិនបានរញ៉េរញ៉ៃទេ គាត់កាប់មួយទំហឹងមិនដឹងមូលហេតុអី ។

៥. តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀប បញ្ជាក់ថា ខ្លួន និងឈ្មោះ [redacted] សុធាប មិនធ្លាប់មានទំនាស់ជាមួយគ្នាទេកន្លងមក។ ប្រពន្ធខ្លួនមានមិត្តភក្តិឈ្មោះ [redacted] ហាត ភេទស្រី ដែលត្រូវជាប្រពន្ធឈ្មោះ [redacted] សុធាប តែគាត់បានលែងលះគ្នាហើយ។ កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង០៥ល្ងាច ខ្លួន និងប្រពន្ធបានទៅចូលរួមកម្មវិធី ហូបចុកនៅផ្ទះឈ្មោះ ឃាម ហាត ដោយមានអ្នកចូលរួមជាច្រើននាក់ លុះវេលាម៉ោង០៩យប់ ពួកខ្លួនឈប់ហូបចុកហើយបន្តច្រៀងលេង ចំណែកខ្លួន កំពុងមើលទូរស័ព្ទស្រាប់តែឈ្មោះ [redacted] សុធាប កាន់កាំបិតខ្វែវសំដៅមកខ្លួននិងកាប់មកលើខ្លួនចំនួន០១ កាំបិតត្រូវចំពីលើក្បាល ហើយពេលនោះឈ្មោះ ស្រ៊ុន បានជួយចាប់ឃាត់ បន្ទាប់មកឈ្មោះ [redacted] សុធាប បានកាន់កាំបិតដើរចេញបាត់ ចំណែកឯខ្លួនត្រូវបានឈ្មោះ ភៀន ដែលជាអ្នកផ្ទះជិតនោះបានដឹកខ្លួនយកទៅព្យាបាលរបួសនៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែត ។ ខ្លួនដេកពេទ្យព្យាបាលរបួសរហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ទើបបានចេញពីមន្ទីរពេទ្យមកព្យាបាលនៅផ្ទះបន្ត។ ពេលនោះរបួសស្នាមខ្លួនមិនទាន់ជាសះស្បើយនៅឡើយ ។

៦. នាពេលសវនាការសាក្សីឈ្មោះ [redacted] ស្រីមុំ បញ្ជាក់ថា ខ្លួនត្រូវជាប្រពន្ធឈ្មោះ [redacted] អៀប ថ្ងៃនោះខ្លួនឈរនៅកន្លែងកើតហេតុឃើញច្បាស់ពេលមកកាប់ ពួកគាត់ឆ្លើយទាំងពីរនាក់និយាយត្រូវ មិនដឹងមូលហេតុអីគាត់កាប់ប្តីខ្លួន ព្រោះប្តីរបស់ខ្លួនអង្គុយលេង ខ្លួននៅច្រៀងមួយបទទៀតថាឈប់ហើយ។ ឈ្មោះ [redacted] សុធាប កាប់ប្តីរបស់ខ្លួន ហើយពីរនាក់ប្តីប្រពន្ធក្បែរនោះជួយប្រតាយក៏ផ្លះកាំបិតឈ្មោះ ហ៊ុន សុធាប បានរើសកាំបិតទៀតតែបានគេឃាត់ជាប់។

៦. ជនជាប់ចោទឈ្មោះ [redacted] សុធាប សារភាពថាបានកាប់ទៅលើជនរងគ្រោះមួយកាំបិត ត្រូវចំក្បាលពិតមែន មិនតែប៉ុណ្ណោះបានដេញថែមទៀត តែត្រូវបានជនរងគ្រោះរត់បាត់ ដែលចម្លើយនេះ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ........ខែ........ឆ្នាំ........ព.ស.២៥៦៤
បន្ទាយមានជ័យ, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner

បង្ហាញតាមរយៈសកម្មភាពកាប់ជាក់ស្តែងជាមួយនឹងស្នាមរបួសត្រង់ក្បាល គឺមានចេតនាឱ្យជនរងគ្រោះស្លាប់ ទោះបីមិនខ្លួនអះអាងថាមិនចង់ឱ្យស្លាប់ក៏ដោយ។

៧. ស្នាមកាប់ ក៏ស៊ីសង្វាក់នឹងចម្លើយរបស់ជនរងគ្រោះ ក៏ដូចជាសាក្សីជាប្រពន្ធរបស់ជនរងគ្រោះដែលនៅកន្លែងកើតហេតុដែរ ដែលថា ជនជាប់ចោទកាប់ហើយ ជ្រុះកាំបិត រើសកាំបិតមករកកាប់ទៀត តែត្រូវបានអ្នកក្បែរនោះឃាត់ទាន់ ដែលនេះបញ្ជាក់កាន់តែច្បាស់ពីចេតនារបស់ជនជាប់ចោទទៅលើជនរងគ្រោះ ក្នុងការកាប់ហើយកាប់ទៀត និងត្រង់កន្លែងដែលអាចស្លាប់បាន។

៨. តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ) នៃក្រមនេះគឺជាបទឃាតកម្ម។

៩. ថ្វីត្បិតតែជនរងគ្រោះមិនស្លាប់ តែបណ្តាលមកពីមានអ្នកនៅកន្លែងកើតហេតុបានជួយឃាត់ និងជនរងគ្រោះរត់គេចខ្លួនប៉ុណ្ណោះ បើមិនដូច្នោះទេ អាចត្រូវជនជាប់ចោទកាប់ស្លាប់មិនខាន។

១០. តាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។

១១. អំពើរបស់ជនជាប់ចោទខាងលើ ដែលបានយកកាំបិតកាប់ខ្វែវ កាប់ត្រង់ក្បាលទៅលើជនរងគ្រោះ ហើយមិនមានចេតនាបញ្ឈប់សកម្មភាពត្រឹមតែកាប់ម្តង តែត្រូវបានរាំងស្ទះដោយអ្នកនៅកន្លែងកើតហេតុ និងការរត់គេចរបស់ជនរងគ្រោះ កំណត់បានជាបទល្មើស **ប៉ុនប៉ងឃាតកម្ម** បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ខាងលើនេះ ។

១២. ជនជាប់ចោទឈ្មោះ [redacted] សុធាប គឺជានីតិជន ដែលមានប្រាជ្ញាស្មារតី និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលខុសចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

១៣. អំពើរបស់ជនជាប់ចោទបានប្រព្រឹត្តធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

១៤. មានធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុធាប ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៩៧៣ (អត្តសញ្ញាណខាងលើ) ពីបទ **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិប្រជាធម្មកើត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ.....ខែ.....ឆ្នាំ.....ស័ក ព.ស.២៥៦៤

បន្ទាយមានជ័យ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

១៥. បណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted] អៀប បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ដោយបានទាមទារសំណងចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល គប្បីតុលាការធ្វើការពិចារណាដោយគិតដល់លទ្ធភាពសងរបស់ជនជាប់ចោទផងដែរ។

១៦. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការថា តាមរបាយការណ៍និងកិច្ចស៊ើបសួរព្រមទាំងបញ្ចប់ការដេញដោលឃើញថាពិតជាមានអង្គហេតុកើតឡើងប្រព្រឹត្តដោយជនជាប់ចោទកាប់ទៅលើជនរងគ្រោះដើម្បីផ្តាច់ជីវិត ច្បាប់កំណត់ជាបទល្មើស **ប៉ុនប៉ងឃាតកម្ម** ស្នើសុំផ្តន្ទាទោសតាមច្បាប់ ដែលការប្តឹងសុំនេះ ត្រឹមត្រូវគប្បីយកមកពិចារណាសម្រេចអំពីទោស។

១៧. សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការថា ក្រោយដេញដោលឃើញថាកូនក្តីរបស់ខ្លួនពិតជាបានប្រព្រឹត្តមែនតែមូលហេតុដោយសារការឌឺដង កូនក្តីរបស់ខ្លួនទទួលស្គាល់កំហុស យល់ដឹងកំហុស មិនធ្លាប់មានទោស សុំផ្តល់ស្ថានសម្រាល ដែលការស្នើសុំនេះ គប្បីយកមកពិចារណាសម្រេចអំពីទោស។

១៨. សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការថា ដោយឯកភាពតាមសហភាតានោះ គប្បីយមកពិចារណាសម្រេចអំពីទោស។

១៩. ជនជាប់ចោទបានសំណូមពរចុងក្រោយថា សុំឲ្យតុលាការបន្ធូរបន្ថយទោស គប្បីតុលាការលើកយកមកពិចារណាសម្រេចអំពីទោស។

## ហេតុដូច្នេះ សាលាដំបូងខេត្តបន្ទាយមានជ័យ

## វិនិច្ឆ័យសេចក្តី

ចំពោះមុខជនជាប់ចោទឈ្មោះ ហ៊ុន សុធាប និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀប

១-ផ្តន្ទាទោសលើជនជនជាប់ចោទឈ្មោះ [redacted] សុធាប ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៩៧៣ ដាក់ពន្ធនាគារកំណត់១០(ដប់)ឆ្នាំ ពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសមានថៃង និងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សុធាប បង់សំណងការព្យាបាល និងជំងឺចិត្តជាប្រាក់សរុបចំនួន១២.០០០.០០០(ដប់ពីរលាន)រៀល ដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀប។ ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ។ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ... ខែ... ឆ្នាំ... ស័ក ព.ស.២៥៦៥

បន្ទាយមានជ័យ, ថ្ងៃទី១៤ ខែ មីនា ឆ្នាំ២០...

ក្រឡាបញ្ជី

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បន្ទាយមានជ័យ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ......ខែ......ឆ្នាំ......ស័ក ព.ស.២៥៦៥

បន្ទាយមានជ័យ ថ្ងៃទី១៨......ខែ......ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]